# សកម្មភាពទី ១ ការគោរពប្រតិបត្តិតាមច្បាប់របស់ព្រះ

- តើមានច្បាប់អ្វីខ្លះនៅក្នុងសហគមន៍របស់អ្នក ?
- តើមានលទ្ធផលអ្វីខ្លះកើតឡើងមកពីការអនុវត្តតាមជាប់លាប់ ឬមិនអនុវត្តតាមច្បាប់ទាំងនោះ ?
- តើការប្រៀបធៀបនេះស្រដៀងគ្នាឬខុសគ្នាពីច្បាប់របស់ព្រះយ៉ាងណា ?

នីហ្វៃ និងអ្នកដើរតាមលោកបានគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ( សូមមើល នីហ្វៃទី ២ ៥:១០ ) ។ សូមអានវគ្គចំណេះចំណានខាងគោលលទ្ធិ ម៉ូសាយ ២:៤១ ហើយរកមើលអ្វីដែលស្ដេចបេនយ៉ាមីនចង់ឲ្យរាស្ត្ររបស់ទ្រង់យល់អំពីការរក្សាបទបញ្ញត្តិរបស់ព្រះ ។ អ្នកអាចពិចារណាធ្វើសេចក្ដីយោងខគម្ពីរនេះទៅនឹង នីហ្វៃទី ២ ៥:១០ ។

- តើអ្នកគិតថាការគោរពប្រតិបត្តិតាមច្បាប់របស់ព្រះជួយយើងឲ្យរីករាយយ៉ាងដូចម្ដេច ?
- តើព្រះយេស៊ូវគ្រីស្ទបានធ្វើជាគំរូដល់ការគោរពប្រតិបត្តិយ៉ាងដូចម្ដេច ?
- តើបទបញ្ញត្តិអ្វីខ្លះរបស់ព្រះដែលបាននាំឲ្យអ្នកមានសុភមង្គលកាន់តែខ្លាំង ?

# សកម្មភាពទី ២ ការងារ និងភាពខ្លួនទីពឹងខ្លួន

នៅលើក្រដាសមួយសន្លឹក ឬក្នុងសៀវភៅកំណត់ហេតុការសិក្សារបស់អ្នក សូមចំណាយពេលបន្តិចដើម្បីធ្វើបញ្ជីអំពីអត្ថប្រយោជន៍ដែលអ្នកនឹងនិយាយថា បានមកពីការខិតខំធ្វើការ ។

សូមអាន នីហ្វៃទី ២ ៥:១១, ១៥, ១៧ ហើយរកមើលរបៀបផ្សេងៗដែលសាសន៍នីហ្វៃបានធ្វើការ និងលទ្ធផលនៃការធ្វើការរបស់ពួកគេ ។

សូមអាន « ការងារ និងភាពខ្លួនទីពឹងខ្លួន » នៅក្នុង *កូនសៀវភៅដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ ២០១១ ) ហើយមើលថា អ្នករៀនបានអ្វីខ្លះអំពីគោលការណ៍នៃការងារ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved.

PD60013873_258_085-teacher_handout-1
PD60013873_258_085-teacher_handout-2